**សុន្ទរកថារបស់ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ**

**ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា**

**ថ្លែងក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នូវគម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយ-លូ**

**ក្នុងរាជធានីភ្នំពេញ ជំហាន៣**

សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន**

សូមគោរព **ឯកឧត្តម ប៉ា សុជាតិវង្ស** អភិបាលនៃគណអភិបាលរាជធានីភ្នំពេញ

សូមគោរពឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោកស្រី និង អស់លោកទាំងអស់

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដែលបានមកចូលរួមពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នូវគម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយ-លូ ក្នុងរាជធានីភ្នំពេញ ជំហាន៣។ ខ្ញុំសូមចូលរួមសម្តែង នូវការអបអរសាទរ ដល់ការសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនេះ ហើយក៏សូមថ្លែងអំណរគុណចំពោះសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង មន្ត្រីគ្រប់ស្ថាបន័ ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងពិធីនេះ។

បរិមាណនៃការបង្ហូរទឹកកខ្វក់ នៅរាជធានីភ្នំពេញ មានការកើនឡើងស្របគ្នាជាមួយនឹងការកើនឡើងយ៉ាងមានស្ថេរភាពនូវកំណើនសេដ្ឋកិច្ច និងចំនួនប្រជាជនកម្ពុជា នៅប៉ុន្មានឆ្នាំថ្មីៗនេះ។ ប្រព័ន្ធប្រឡាយ-លូនៅក្នុងរាជធានីក៏ចាប់ផ្តើមមានសភាពចាស់ទ្រុឌទ្រោម ជាពិសេសនៅរដូវវស្សាបង្កឲ្យមាននូវការខូចខាតដូចជាទឹកលិចផ្ទះប្រជាពលរដ្ឋ និងផ្លូវថ្នល់ជាដើម។

ជំនួយលើគម្រោងការពារទឹកជំនន់ដែលជប៉ុនបានផ្តល់ដល់រាជធានីភ្នំពេញមានដូចជា ការរៀបចំបង្កើតប្លង់មេ (Master Plan) នៅឆ្នាំ១៩៩៩ និងយោងតាមប្លង់នេះ ជប៉ុនបានអនុវត្តនូវគម្រោងជំនួយឥតសំណងចំនួន៣ជំហានហើយ  តាំងពី ឆ្នាំ២០០១ មក។ គម្រោងជំហាន១ និងជំហាន២ ផ្តោតសំខាន់លើការពង្រឹងនូវទំនប់ការពារការជួសជុលប្រព័ន្ធប្រឡាយ-លូ និងការកែលម្អស្ថានីយបូមទឹក នៅតំបន់ភាគនិរតី និងតំបន់ភាគឦសាន នៅក្នុងរាជធានីភ្នំពេញ។

ខ្ញុំមានសេចក្តីសប្បាយរីករាយ ដោយឃើញសួនច្បារមាត់ទន្លេ ដែលត្រូវបានរៀបចំឡើងក្រោមកិច្ចសហការគ្នារវាងរាជធានីភ្នំពេញ និងជប៉ុន ក្រោមគម្រោងជំហានទី២ បានក្លាយទៅជាទីកន្លែងសម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងភ្នំពេញ និងភ្ញៀវទេសចរណ៍មកសម្រាកកំសាន្ត។

ជំនួយគម្រោងជំហាន៣ ដែលសម្ពោធនៅថ្ងៃនេះ បានអនុវត្តនូវការរៀបចំបំពង់លូថ្មី កែលម្អអាងស្តុកទឹកនៅជុំវិញតំបន់ភាគអាគ្នេយ៍នៃរាជធានីភ្នំពេញ និងផ្តល់ជូននូវរថយន្តចំនួន៨គ្រឿង រួមទាំងបានផ្តល់ការណែនាំនូវបច្ចេកទេស ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងនិងថែរក្សា ។

រហូតមកដល់ពេលនេះ មានករណីសំរាមស្ទះក្នុងបំពង់លូដែលរៀបចំហើយ ធ្វើអោយការបង្ហូរទឹកមិនសូវមានប្រសិទ្ធិភាព។ ខ្ញុំសង្ឃឹមថា រថយន្តបូមលូចំនួន៤គ្រឿង និងរថយន្តលាងសម្អាតលូសម្ពាធខ្ពស់ចំនួន៤គ្រឿង ដែលបានផ្តល់ជូន នឹងត្រូវបានប្រើប្រាស់សមស្របទៅតាមគម្រោងគ្រប់គ្រងនិងថែរក្សាដែលបានរៀបចំឡើង ដើម្បីលើកកម្ពស់ប្រសិទ្ធិភាពនៃការបង្ហូរទឹកក្នុងប្រព័ន្ធប្រឡាយ-លូ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ប្រជាពលរដ្ឋ ហាងលក់សម្ភារៈ ផ្សារនៅក្នុងតំបន់ និងទីកន្លែងសាធារណៈ ដែលធ្លាប់តែទទួលរងការខូតខាតជាទម្ងន់នៅរដូវវស្សា នឹងអាចជៀសផុតពីការទទួលរងគ្រោះធំៗបាន ដោយសារការរៀបចំកែលំអនូវប្រព័ន្ធប្រឡាយ-លូ និងការផ្គត់ផ្គង់គ្រឿងបរិក្ខារលើកនេះ។

ជាចុងក្រោយ តាងនាមឲ្យរដ្ឋាភិបាល និងប្រជាជនជប៉ុន ខ្ញុំសូមសម្តែងនូវអំណរគុណសារជាថ្មីម្តងទៀតចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានចូលរួមខិតខំប្រឹងប្រែងក្នុងការអនុវត្តគម្រោងនេះ ហើយខ្ញុំក៏សង្ឃឹមយ៉ាងស្មោះសរផងដែរថា ប្រព័ន្ធប្រឡាយ-លូដែលបានរៀបចំឡើងនិងគ្រឿងបរិក្ខារទាំងឡាយដែលបានផ្តល់ជូនក្នុងគម្រោងនេះ នឹងចូលរួមជាយូរអង្វែងក្នុងចំណែកដ៏ធំមួយ ដើម្បីប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងភ្នំពេញ និងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមរបស់ប្រទេសកម្ពុជា។

សូមអរគុណ។